# ដំណឹងជ្រើសរើសបុគ្គលិក

## តួនាទី៖ គ្រូបង្រៀនភាសាខ្មែរ

សាលារៀន ញូវវីសិន ជាគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន ចាប់ពីកម្រិតមត្តេយ្យសិក្សាដល់បឋមសិក្សា ដែលប្រកាន់យកគុណតម្លៃជាគ្រីស្ទបរិស័ទ។ សាលារៀន ចាប់ដៃគូជាមួយគ្រួសារកុមារជាសិស្សានុសិស្ស ដើម្បីស្វះស្វែងឱ្យក្លាយជាសាលារៀនតែមួយគត់ ក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ និងតម្លៃសមរម្យ។

សាលារៀនញូវវីសិន ត្រូវការជ្រើសរើសបុគ្គលិកខ្មែរដើម្បីបំពេញតួនាទីជា៖
**គ្រូបង្រៀនចំណេះទូទៅភាសាខ្មែរ កម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា**

ទីកន្លែង៖ **ឫស្សីកែវ ភ្នំពេញ**

**<u>គោលបំណងនៃការងារ</u>**

មានកាតព្វកិច្ចបង្រៀនប្រកបដោយវិជ្ជាជីវៈ ទទួលខុសត្រូវក្នុងការគ្រប់គ្រងថ្នាក់រៀន គ្រប់គ្រងវិន័យសិស្សឱ្យមានប្រសិទ្ធិភាព និង ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ជាគ្រូបង្រៀន គោលការណ៍ផ្សេងៗ កម្មវិធីសិក្សា និងប្រតិទិនសិក្សាប្រចាំឆ្នាំរបស់សាលារៀន។

**<u>ភារកិច្ច និងការទទួលខុសត្រូវសំខាន់ៗ</u>**

- រៀបចំ និងធ្វើផែនការមេរៀន(ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍) ដើម្បីបង្រៀនតាមកម្មវិធីសិក្សា ដោយប្រើវិធីសាស្ត្រនិងយុទ្ធសាស្ត្របង្រៀនដែលទទួលបានការណែនាំ និងហ្វឹកហ្វឺនពីសាលារៀន។
- ទទួលខុសត្រូវលើការត្រួតពិនិត្យ វាយតម្លៃ កត់ត្រា និងរាយការណ៍អំពីការរីកចម្រើននៃការសិក្សា ការរីកលូតលាស់នៃបញ្ញាស្មារតី រូបរាងកាយ អាកប្បកិរិយា អនាម័យសុខភាព និងផ្លូវចិត្តរបស់សិស្ស។
- សង្កេតពីតម្រូវការនៃសមត្ថភាព និងភាពខ្វះខាតរបស់សិស្សម្នាក់ៗ ដើម្បីសហការណ៍ជាមួយថ្នាក់ដឹកនាំសាលារៀន ក្នុងការរៀបចំវិធីសាស្ត្របង្រៀនសម្បូរបែបក្នុងការឆ្លើយតបទៅនឹងភាពខ្វះខាត់របស់សិស្ស។
- ធ្វើការប្រាស្រ័យទាក់ទងជាមួយមាតាបិតាឬអ្នកអាណាព្យាបាលសិស្ស និងអ្នកគ្រប់គ្រង អំពីផ្នែកផ្សេងៗនៃការអប់រំរបស់សិស្ស៖ ផ្នែកការសិក្សា ផ្នែកទំនាក់ទំនងសង្គម ឬផ្នែកផ្លូវអារម្មណ៍ ហើយនិងរក្សាការសម្ងាត់គ្រប់ពេលជានិច្ច។

- បំពេញកាតព្វកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានផ្នែក និង/ឬសាលារៀន។

## <u>លក្ខណសម្បត្តិ</u>

- កំពុងបន្ត ឬបញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬវិញ្ញាបនបត្រដែលមានតម្លៃស្មើ
- មានបទពិសោធន៍ផ្នែកបង្រៀន
- មានឥរិយាបថសុភាពរាបសារ តែម៉ឺងម៉ាត់ចំពោះការងារ និងទំនួលខុសត្រូវ
- មានទេពកោសល្យអប់រំសីលធម៌ ចរិយាធម៌ និងវិន័យ
- គោរពពេលវេលា ស្រឡាញ់ការអប់រំ ចូលចិត្តកុមារ និងមានទំនាក់ទំនងល្អជាមួយមិត្តរួមការងារ
- មានឆន្ទៈ និងព្យាយាមរៀនសូត្រនូវអ្វីដែលថ្មីៗ និងចូលរួមកម្មវិធីផ្សេងៗទាក់ទិននឹងការងារ
- គោរពគុណតម្លៃគ្រីស្ទបរិស័ទរបស់សាលារៀន
- មានប័ណ្ណចាក់វ៉ាក់សាំង កូវីដ-19។

## <u>ការដាក់ពាក្យ</u>

បេក្ខជនដែលចាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបដោយសរសេរព័ត៌មានលម្អិត មិនឱ្យលើសពី**ថ្ងៃទី22 ខែមករា ឆ្នាំ2022** វេលាម៉ោង5:00 ល្ងាច មកសាលារៀនញូវីសិន ដែលមានអាសយដ្ឋាន ផ្ទះលេខ៨២៣ ផ្លូវ៣R ភូមិមិត្តភាព សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ ភ្នំពេញ ទូរស័ព្ទលេខ 092/090/070 - 99 77 86 ឬផ្ញើតាមរយៈតេលេក្រាម 086 838 880 ឬអ៊ីម៉ែល hr@newvisionschool.net

បេក្ខជនដែលដាក់ប្រវត្តិរូបមុន អាចនឹងត្រូវបានទាក់ទងមកសម្ភាសន៍មុន។ បេក្ខជនដែលទទួលបានជោគជ័យ នឹងតម្រូវឱ្យគោរពតាមក្បួនច្បាប់គោលនយោបាយបុគ្គលិក ក៏ដូចជាគោលនយោបាយការការពារកុមាររបស់សាលារៀនញូវីសិន។